# ឆ្នាំថ្មី ! ! !

បុណ្យចូលឆ្នាំថ្មីប្រុសស្រីសប្បាយ

ហាក់ដូចឃ្លាតឆ្ងាយពីក្ដីមរណា

តែបើពិនិត្យអាយុសង្ខារ

ពិតឃើញច្បាស់ថាជីវិតអស់ពេលហើយ ៗ

ហាមបោះពុម្ពចែកជាបន្តដោយមិនមានការអនុញ្ញាតពីម្ចាស់សៀវភៅ

# ព្រះធម្មបទ ៣៣ គាថា



## ចំណងដៃឆ្នាំថ្មី

រៀបរៀងដោយ

ភិក្ខុវជិរប្បញ្ញោ សាន សុជា

សម្រាប់ជាធម្មទាន



ភិក្ខុវជិរប្បញ្ញោ សាន សុជា

ក្នុងជន្មាយុ ៣២ ព្រះវស្សា

# មាតិការអត្ថបទ

**ឈ្មោះធម៌** **ទំព័រ**

ពាក្យប្រារព្ធ.................................... ក

XII. គាថាព្រះធម្មបទ អត្តវគ្គ(ត)

គាថាទី ១ .................................... ១

គាថាទី ២ .................................... ៤

គាថាទី ៣ .................................... ៧

គាថាទី ៤ .................................... ១០

គាថាទី ៥ .................................... ១៣

គាថាទី ៦ .................................... ១៦

គាថាទី ៧ .................................... ១៩

គាថាទី ៨ .................................... ២២

គាថាទី ៩ .................................... ២៥

## XIII. គាថាព្រះធម្មបទ លោកវគ្គ(ត)

គាថាទី ១០ .................................... ២៨

គាថាទី ១១ .................................... ៣១

គាថាទី ១២ .................................... ៣៥

គាថាទី ១៣ .................................... ៣៨

គាថាទី ១៤ .................................... ៤១

គាថាទី ១៥ .................................... ៤៤

គាថាទី ១៦ .................................... ៤៧

គាថាទី ១៧ .................................... ៥១

គាថាទី ១៨ .................................... ៥៤

គាថាទី ១៩ .................................... ៥៧

គាថាទី ២០ .................................... ៦០

## XIV. គាថាព្រះធម្មបទ ពុទ្ធវគ្គ

គាថាទី ២១ .................................... ៦៣

គាថាទី ២២ .................................... ៦៨

គាថាទី ២៣ .................................... ៧១

គាថាទី ២៤ .................................... ៧៤

គាថាទី ២៥ .................................... ៨១

គាថាទី ២៦ .................................... ៨៥

គាថាទី ២៧ .................................... ៩២

គាថាទី ២៨ .................................... ៩៥

គាថាទី ២៩ .................................... ៩៨

## XV. គាថាព្រះធម្មបទ សុខវគ្គ


គាថាទី ៣០ .................................... ១០២

គាថាទី ៣១ .................................... ១០៧

គាថាទី ៣២ .................................... ១១០

គាថាទី ៣៣ .................................... ១១៣

អ្នកជួយពិនិត្យអក្ខរាវិរុទ្ធ...................... ១១៦

សៀវភៅដែលបានរៀបរៀង................. ១១៧

ប៉ុស្តិ៍វិទ្យុដែលកំពុងផ្សាយព្រះធម៌........... ១១៩

ឈ្មោះអ្នកឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ ១២១

ពុទ្ធបរិស័ទអ្នកឧបត្ថម្ភប្រាក់បោះពុម្ព........ ១២៣

ឈ្មោះអ្នកចូលកសាងកុដិលេខ ២៩.......... ១៤៨

ដំណឹងកសាងបទុមចេតិយ...................... ១៥៨




## ពាក្យប្រារព្ធ

ពុទ្ធបរិស័ទទាំងឡាយ ! ពេលវេលានៃការរស់នៅរបស់មនុស្សយើងនេះ មិនសម្បូរឡើយ ធ្មេចបើក ៗ ជិតដល់ពេលស្លាប់ទៅហើយ ហើយចំពោះជីវិតដែលខ្លីយ៉ាងនេះ តើយើងធ្លាប់បានគិតដែរឬទេថា ការងារជាប្រយោជន៍សម្រាប់ខ្លួនឯងអាត្មាអញបានធ្វើប៉ុនណាហើយ ? និងការងារដែលមិនទាន់ធ្វើ នៅមានអ្វីខ្លះទៀត ? ម្យ៉ាងទៀតការងារជាប្រយោជន៍ដល់អ្នកដទៃ និងជាប្រយោជន៍ដល់ប្រទេសជាតិ ឬក៏ដើម្បីព្រះសាសនា អាត្មាអញធ្វើបានប៉ុនណាហើយ ? តទៅខាងមុខនឹងធ្វើអ្វីទៀត ?

កាលបើយើងឧស្សាហ៍គិតយ៉ាងនេះ យើងពិត

ជាយល់ឃើញនូវតម្លៃពិតប្រាកដ របស់ពេលវេលា មិនខានឡើយ ។

តាមដែលខ្ញុំដឹង អ្នកប្រាជ្ញសម័យបុរាណខ្លះ ដូចជាសម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ **ជួន ណាត** ជាដើម បានចំណាយពេលវេលាអស់មួយជីវិត របស់លោកទៅហើយ ក្នុងការបំពេញការងារដើម្បី ខ្លួនព្រះអង្គផ្ទាល់ ដើម្បីព្រះសាសនា និងដើម្បីប្រទេស ជាតិ ប៉ុន្តែក៏នៅមិនទាន់អស់កិច្ចការជាប្រយោជន៍ ដែលត្រូវបំពេញនោះដែរ ។

ដែលខ្ញុំលើកឡើងយ៉ាងនេះ ដើម្បីដាស់គំនិត យើងគ្រប់គ្នាថា បើពេលវេលាមិនសម្បូរយ៉ាងនេះ ហេតុអ្វីក៏យើងនៅតែចំណាយពេលវេលា ទៅក្នុងរឿង



ឥតប្រយោជន៍ផ្សេង ៗ ដូចជាការដើរលេងយប់ ការ ប្រព្រឹត្តអបាយមុខ ឬក៏និយាយគ្នាលេងជាដើមច្រើន ម្ល៉េះ ? តើអ្នកទាំងអស់គ្នានោះ ក្នុងម្នាក់ ៗ មានជីវិត ប៉ុន្មាន ? ហើយអាចរស់នៅបានពេលយូរប៉ុនណា ទៀត ? បើមិនបានបំពេញការងារជាប្រយោជន៍ដល់ ខ្លួនឯង និងអ្នកដទៃទេ តើខ្លឹមសារនៃការរស់យូរ នោះនៅត្រង់ណាខ្លះទៅ ? សូមពុទ្ធបរិស័ទបាន ពិចារណាដោយល្អចុះ ។

ឆ្នាំថ្មីនេះ គឺឆ្នាំឆ្លូវ ឯកស័ក ព.ស.២៥៥៣ ខ្ញុំមានអាយុ ៣៣ ឆ្នាំទៅហើយ ឃើញថាចាស់ដែរហើយ ឯមច្ចុរាជ ក៏បានបញ្ជូនសេនាមកចាត់ការជារៀងរាល់ថ្ងៃ ហើយការយកឈ្នះលើមច្ចុរាជនោះ មិនមានសោះ

ឡើយ សេចក្តីស្លាប់ពិតជាមកដល់មិនខាន តែខ្ញុំពេញចិត្តណាស់ចំពោះពេលវេលា ដែលបានអនុញ្ញាតឱ្យខ្ញុំបំពេញការងារជាប្រយោជន៍បានបន្តិចបន្តួច ដូចសព្វថ្ងៃនេះ មុនពេលដែលសេចក្តីស្លាប់មកដល់ ។

ដើម្បីវាស់វែងទៅនឹងពេលវេលា ៣៣ ឆ្នាំ ដែលខ្ញុំបានរស់កន្លងមកហើយ ខ្ញុំក៏លើកបទធម៌ចំនួន ៣៣ ព្រះគាថា មកសរសេរប្រគេន និងចែកជូនជាធម្មទានក្នុងឱកាសបុណ្យចូលឆ្នាំថ្មីខាងមុខនេះ ។

ម្យ៉ាងទៀត ក្នុងការរៀបរៀងនេះ ខ្ញុំបានដកស្រង់ភាសាអង់គ្លេស ពីសៀវភៅធម៌បរទេស ដែលប្រែចេញពីភាសាបាលីដូចគ្នា មកសរសេរជាមួយផង ដោយសង្ឃឹមថា នឹងបានជាប្រយោជន៍ដល់អ្នកចេះភាសានេះ ។



សូមឧទ្ទិសនូវកុសល ដែលកើតឡើងអំពីការងារធម្មទាននេះ ចំពោះអ្នកដែលចែកឋានទៅហើយដូចជា :

-បុរាណបណ្ឌិតខ្មែរគ្រប់ជំនាន់

-ព្រះភិក្ខុ **ញ៉ៀម ទ៉ាន់** ជាព្រះឧបជ្ឈាយ៍របស់ខ្ញុំ

-ព្រឹទ្ធាចារ្យ **អៀង យ៉ង** ជាជីតារបស់ខ្ញុំ

-ព្រឹទ្ធាចារ្យ **ឌុន សាន** ជាជីតារបស់ខ្ញុំ

-ឧបាសិកា **សុខ គ្រីស** ជាជីដូនរបស់ខ្ញុំ

-ប្អូនប្រុស **សាន សុខ** និងប្អូនប្រុស **សាន សាវឿន**

សូមជូនចំពោះ ជីដូនរបស់ខ្ញុំ **ហែម ផាន់** ញោមប្រុស **សាន ឌុយ** ញោមស្រី **អៀង ចែម** ដែលកំពុងមានជីវិតរស់នៅសព្វថ្ងៃ និងពពួកញាតិក្នុងសង្សារវដ្តទាំងអស់ ។

មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ឃុំរលាប ស្រុកសំពៅមាស
ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា
ថ្ងៃសៅរ៍ ១៤ រោច ខែ បុស្ស ឆ្នាំ ឆ្លូវ សីរិទ្ធិស័ក ព.ស.២៥៥២

**ភិក្ខុវជិរប្បញ្ញោ សាន សុជា**

## គាថាទី ១ (១)

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះឧបនន្ទ ជាបុត្តនៃស្តេច សក្យៈ ទើបត្រាស់នូវព្រះគាថានេះថា

**អត្តានមេវ បឋមំ**

**បដិរូបេ និវេសយេ**

**អថញ្ញមនុសាសេយ្យ**

**ន កិលិស្សេយ្យ បណ្ឌិតោ ។**

បណ្ឌិត គួរតម្កល់ខ្លួនទុកក្នុងគុណដ៏សមគួរជា មុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃ ជាខាង ក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ ។

---

១-បើរាប់តាមលំដាប់ក្នុងអត្តវគ្គ ត្រូវជាគាថា ទី ២

# ADVISERS SHOULD SET THE EXAMPLE FIRST

Let one first establish oneself in what is proper, and then instruct others. Such a wise man will not be defiled.[1]

1. Will not be blamed by others.



បុគ្គលជាបណ្ឌិត　　មានគំនិតគិតប្រពៃ
ដំបូងត្រូវកែខៃ　　លៃតម្កល់ខ្លួនឱ្យល្អ ។
រួចសឹមទៅទូន្មាន　　ប្រៀនប្រដៅសត្តនិករ
ប្រាកដបានផលល្អ　　រឿងរិកវរមិនមានឡើយ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

## គាថាទី ២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះតិស្សត្ថេរ អ្នកប្រកបនូវសេចក្តីព្យាយាម ទើបត្រាស់នូវព្រះគាថានេះថា

**អត្តានញ្ចេ តថា កយិរា**
**យថញ្ញមនុសាសតិ**
**សុទន្តោ វត ទមេថ**
**អត្តា ហិ កិរ ទុទ្ទមោ ។**

បុគ្គល ប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឱ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់ ។



## ACT AS YOU INSTRUCT

As he instructs others so should he himself act. Himself fully controlled, he should control (others); for oneself, indeed, is difficult to control.

បុគ្គលប្រដៅគេយ៉ាងណា

ត្រូវធ្វើចរិយាឱ្យសមរម្យ

កុំឃើញទោសគេទាំងតូចធំ

ទោសខ្លួនប៉ុនភ្នំសម្ងំលាក់ ។

កុំធ្វើគីង្គក់លក់ថ្នាំស្រែង

កំហុសខ្លួនឯងមើលពុំជាក់

ត្រូវទូន្មានខ្លួនឱ្យដល់ថ្នាក់

ព្រោះខ្លួនលំបាកទូន្មានណាស់ ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***



## គាថាទី ៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវមាតារបស់ព្រះកុមារកស្សបៈ ទើបត្រាស់នូវព្រះគាថានេះថា

**អត្តា ហិ អត្តនោ នាថោ**

**កោ ហិ នាថោ បរោ សិយា**

**អត្តនា ហិ សុទន្តេន**

**នាថំ លភតិ ទុល្លភំ ។**

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹងដែលគេបានដោយកម្រ ។

# SELF IS ONE'S REFUGE

Oneself is one's own protector (refuge); what other protector (refuge) can there be? With oneself fully controlled, one obtains a protection (refuge) which is hard to gain.



ខ្លួនជាទីពឹងនៃខ្លួនឯង
ព្រះពុទ្ធសម្តែងយ៉ាងជាក់ច្បាស់
ពឹងអ្នកដទៃលំបាកណាស់
ព្រោះអាចនឹងប៉ះការខកចិត្ត ។
ថាបើបុគ្គលបានប្រឹងប្រែង
ទូន្មានខ្លួនឯងដល់កម្រិត
នឹងបានទីពឹងសមដូចចិត្ត
គេពិតជារកបានដោយក្រ ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវឧបាសក អ្នកជាសោតាបន្នឈ្មោះមហាកាល ទើបត្រាស់នូវព្រះគាថានេះថា

**អត្តនា ហ កតំ បាបំ**

**អត្តជំ អត្តសម្ភវំ**

**អភិមត្ថតិ ទុម្មេធំ**

**វជិរំវម្ហមយំ មណឹ ។**

បាបកើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណី ដែលកើតអំពីថ្ម ដូច្នោះឯង ។



## ONE IS RESPONSIBLE FOR ONE'S EVIL

The evil done by oneself, arising in oneself, and caused by oneself, destroys the foolish one, just as a diamond grinds a hard gem.

បាបកើតពីខ្លួនឯង ក្មានអ្នកផ្សេងធ្វើឱ្យឡើយ

អំពើបាបហ្នឹងហើយ តែងញាំញីអ្នកធ្វើបាប ។

ដូច្នេះត្រូវសាងល្អ កុំបន្តកម្មថោកទាប

សាងគុណលះក្លិនឆ្អាប បាបកំណាចតាមមិនទាន់ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**



## គាថាទី ៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវព្រះទេវទត្ត ទើបត្រាស់នូវព្រះគាថានេះថា

**យស្ស អច្ចន្តទុស្សីល្យំ**
**មាលុវា សាលមិវោត្ថតំ**
**ករោតិ សោ តថត្តានំ**
**យថា នំ ឥច្ឆតី ទិសោ ២**

ភាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់ (នូវអត្តភាព) របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះឈ្មោះថា ធ្វើខ្លួនឯងឱ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គលនោះឱ្យវិនាសដូច្នោះ ។

# THE CURRUPT BRING ABOUT THEIR OWN RUIN

As the creeper (māluvā) strangles the sal tree, so also, a really immoral person (overwhelmed by craving) does to himself just what his enemy wishes him to suffer.



គំនិតខូចខិល សភាពទ្រុស្តសីល ធ្លាក់លើអ្នកណា
អ្នកនោះមុខជា អន្តរាយអាត្មា ដូចដើមរុក្ខា
ស្លាប់ដោយវល្លិ៍ជ្រៃ ។
ពុំនោះដូចជា ចោរចិត្តមោហា បៀតបៀនប្រល័យ
បុគ្គលនោះឯង ឥតត្រាប្រណី រហូតដល់ក្ស័យ
សូន្យចាកសង្ខារ ។

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

# EVIL IS EAZY BUT GOOD IS DIFFICULT

Easy to do are things that are evil and not beneficial to oneself, but very difficult indeed, to do is that which is beneficial and good.

កម្មមិនល្អ ឥតប្រយោជន៍ ជាកម្មខ្មៅ
ពាលកម្លៅ តែងតែធ្វើ បានដោយងាយ
តែកម្មល្អ មានប្រយោជន៍ ផុតអន្តរាយ
ពាលមិនងាយ នឹងប្រព្រឹត្ត ធ្វើបានឡើយ ។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**



## គាថាទី ៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះកាលត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ**
**បដិក្កោសតិ ទុម្មេធោ ទិដ្ឋឹ និស្សាយ បាបិកំ**
**ផលានិ កណ្ឌកស្សេវ អត្តឃញ្ញាយ ផល្លតិ ។**

បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមកហាមឃាត់សាសនា របស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញផលដើម្បីសម្លាប់ខ្លួន ដូចផ្លែឫស្សីដូច្នោះ ។

# ORN NOT THE NOBLE

The foolish man, who, on account of false views, scorns the teaching of the Arahants, the Noble Ones, and the Righteous, produces fruit like the bamboo, only for self-destruction.



បុគ្គលអប្បប្រាជ្ញា ព្រោះមោហាបាំងសន្ដាន
មានទិដ្ឋិសាមាន្យ ហ៊ានពោលស្ដីឥតអៀនខ្មាស ។
ហាមឃាត់ព្រះសាសនា ដែលសាស្ដាទ្រង់ប្រកាស
ផលតបពិតចេញច្បាស់ ដូចឫស្សីស្លាប់ព្រោះផ្លែ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវឧបាសកឈ្មោះចុល្លកាល ទើបត្រាស់នូវព្រះគាថានេះថា

**អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ**
**អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ**
**សុទ្ធិ អសុទ្ធិ បច្ចត្តំ**
**នាញ្ញោ អញ្ញំ វិសោធយេ ។**

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធិ នឹងមិនបរិសុទ្ធិ មានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃឱ្យបរិសុទ្ធពុំបានទេ ។



## PURITY AND IMPURITY DEPEND ON ONESELF

By oneself, indeed, is evil done; by oneself is one defiled. By oneself is evil left undone; by oneself, indeed, is one purified. Purity and impurity depend on oneself. No one purifies another.

អ្នកធ្វើបាប តែងសៅហ្មង ដោយខ្លួនឯង
គ្មានអ្នកផ្សេង មកសៅហ្មង ជំនួសឡើយ
តែបើអ្នក មិនធ្វើបាប ខ្លួនឯងហើយ
កុំឆ្ងល់ឡើយ អ្នកនឹងផុត ភាពសៅហ្មង ។
ព្រោះហេតុថា អាក្រក់ឬ បរិសុទ្ធ
ខ្លួនម្នាក់គត់ ទើបដឹងច្បាស់ ជាងអ្នកផង
បើចង់ស្អាត បរិសុទ្ធ អស់សៅហ្មង
កុំរំលង បុណ្យកុសល រាល់យប់ថ្ងៃ ។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ង.***



## គាថាទី ៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវអត្តទត្ថត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**អត្តទត្ថំ បរត្ថេន**
**ពហុនាបិ ន ហាបយេ**
**អត្តទត្ថមភិញ្ញាយ**
**សទត្ថបសុតោ សិយា ។**

បុគ្គលកុំគប្បីធ្វើប្រយោជន៍ខ្លួនឱ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន (នោះ) ។

# STRIVE FOR YOUR SPIRITUAL WELFARE

For the sake of others' welfare, however great, let not one neglect one's own welfare.[1] Clearly perceiving one's own welfare, let one be intent on one's own goal.

---

1. Here "welfare' denotes one's ultimate goal, i.e., Nibbāna. Personal sanctification should not be sacrificed for the sake of external homage. One must not misunderstand this verse to mean that one should not selflessly work for the weal of others. Selfless service is highly commended by the Buddha.



កុំលះខ្លួនចោលក្នុងសង្សារ
ព្រោះគិតអាងថាជួយអ្នកផង
ប្រយោជន៏ខ្លួនឯងកុំរំលង
អ្នកផងជួយរងមិនរួចទេ ។
កុំស៊ូធ្វើបាបព្រោះញាតិផៅ
ព្រោះពេលស្លាប់ទៅទាំងយើងគេ
គ្រប់យ៉ាងយកទៅមិនរួចទេ
មានតែបាបបុណ្យជាមតិក ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

## គាថាទី ១០[(១)]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុកំលោះមួយរូប ទើបត្រាស់នូវព្រះគាថានេះថា

**ហីនំ ធម្មំ ន សេវេយ្យ**

**បមាទេន ន សំវសេ**

**មិច្ឆាទិដ្ឋឹ ន សេវេយ្យ**

**ន សិយា លោកវឌ្ឍនោ ។**

បុគ្គលមិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្ដីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោក ។

---

១-បើរាប់តាមលំដាប់ក្នុងលោកវគ្គ ត្រូវជាគាថា ទី ១



# GIVE UP BASE DESIRES

Do not follow a life of evil; do not live heedlessly; do not have false views; do not value worldly things. (In this way one can get rid of suffering).

បុគ្គលមិនគួរសេព　និត្យនៅអែបធម៌ថោកទាប
ជាធម៌មានក្លិនឆ្អាប　បានដល់កាមគុណប្រាំ ។
មិនគប្បីប្រមាទ　ត្រូវសង្វាតជាប្រចាំ
លះទិដ្ឋិសាំញ៉ាំ　កុំជាមនុស្សចង្អៀតលោក ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**



## គាថាទី ១១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធនូវព្រះបិតា ទើបត្រាស់នូវព្រះគាថានេះថា

**ឧត្តិដ្ឋេ នប្បមជ្ជេយ្យ**
**ធម្មំ សុចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ**
**អស្មឹ លោកេ បរម្ហិ ច ។**
**ធម្មំ ចរេ សុចរិតំ**
**ន តំ ទុច្ចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ**
**អស្មឹ លោកេ បរម្ហិ ច ។**

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធមិឱ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធមិជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គលគួរប្រព្រឹត្តធមិឱ្យសុចរិត មិនគួរប្រព្រឹត្តធមិនោះឱ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធមិជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។



## THE RIGHTEOUS ARE HAPPY

A man should not live heedlessly but should exert himself to live righteously. Such a man is happy in this world and in the next.

## BE RIGHTEOUS

A man should live righteously and not wrongly. Such a man is happy in this world and in the next.

បព្វជិត ពិតមិនគួរ កើតប្រមាទ
ក្នុងបិណ្ឌបាត ដែលខ្លួនបាន ក្រោកទទួល
ត្រូវប្រព្រឹត្ត សុចរិត តាមសម្រួល
លះទទួល គឺកិលេស ពួកធម៌ហីន៏ ។
ព្រោះបុគ្គល ចេះគួរគិត គំនិតល្អ
ប្រព្រឹត្តធម៌ ក្នុងជីវិត ប្រក្រតី
តែងតែបាន ដេកជាសុខ ក្នុងលោកីយ៍
លោកដទៃ ដែលខ្លួនទៅ ក៏បានសុខ ។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ឌ.**



## គាថាទី ១២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយ អ្នកចម្រើននូវវិបស្សនា មានប្រមាណ ៥០០ រូប ទើបត្រាស់នូវព្រះគាថានេះថា

**យថា បុព្វុឡកំ បស្សេ**
**យថា បស្សេ បរីចិកំ**
**ឯវំ លោកំ អវេក្ខន្តំ**
**មច្ចុរាជា ន បស្សតិ ៕**

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រិញថ្ងៃយ៉ាងណា ស្ដេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

# LIKE A BUBBLE IS THIS WORLD

Just as one would look upon a bubble, just as one would look upon a mirage[1] – if a person thus looks upon the world, the King of Death sees him not.

---

1. This psycho-physical organism is to be regarded as being as empty as a bubble and as illusive as a mirage. The wise man who could so regard it would end the ills of life.



បុគ្គលអ្នកកាលពិចារណា
ឃើញខន្ធលោកថាមិនឋិតថេរ
កើតហើយមិនទៀងតែងប្រួលប្រែ
ព្រោះតែជាផលនៃបច្ច័យ ។
ដែលមើលឃើញដូចពពុះទឹក
ឬនឹកថាដូចជាព្រិញថ្ងៃ
ដូច្នេះការរស់ពិតជាថ្លៃ
មច្ចុចង្រៃមើលមិនឃើញ ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

## គាថាទី ១៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវអភយរាជកុមារ ទើបត្រាស់នូវព្រះគាថានេះថា

**ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ**
**យត្ថ ពាលា វិសីទន្តិ**
**នត្ថិ សង្គោ វិជានតំ ។**

អ្នកទាំងឡាយ ចូរមកមើលលោកនេះ ដ៏ត្រកាលដូចរាជរថ ជនពាលទាំងឡាយ រមែងលិចលង់ក្នុងលោកណា សេចក្ដីជាប់ជំពាក់ក្នុងលោកនោះ រមែងមិនមាន ដល់ជនជាបណ្ឌិតទាំងឡាយដែលដឹងច្បាស់ទេ ។



## THE WISE ARE NOT ATTACHED TO THE WORLD

Come, behold this world[1] which is like unto an ornamented royal chariot, wherein fools flounder, but for the wise there is no attachment.

---

1. This body, composed of the five Aggregates.

នែ! អ្នកទាំងឡាយមើលលោកនេះចុះ
ស្រស់ល្អចម្រុះដូចជារាជរថ
ដែលពួកជនពាលតែងតែភ្លាំងភ្លាត់
លិចលង់ប្រតិព័ទ្ធនៅក្នុងលោកណា ។
តែការជំពាក់នៅក្នុងលោកនោះ
មិនមានចំពោះអ្នកមានប្រាជ្ញា
ព្រោះលោកឃើញច្បាស់ក្នុងរឿងសង្ខារ
ទោះស្រស់យ៉ាងណាក៏លោកមិនលង់ ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***



# គាថាទី ១៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះសម្មជ្ជនត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**យោ ច បុព្វេ បមជ្ជិត្វា**
**បច្ឆា សោ នប្បមជ្ជតិ**
**សោមំ លោកំ បភាសេតិ**
**អព្ភា មុត្តោវ ចន្ទិមា ៕**

បុគ្គលណាមួយកាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញុំាងខន្ធាទិលោកនេះឱ្យភ្លឺច្បាស់ ដូចព្រះចន្ទ្ររះផុតចាកពពក ។

# THE HEEDFUL ILLUMINE THE WORLD

A man, who is free from heedlessness and is heedless no more, purifies himself and shines in this world like the moon which is freed from a cloud.



បុគ្គលណា ធ្លាប់ប្រមាទ គ្រាកន្លង
ធ្លាប់ឆ្គាំឆ្គង ប្រព្រឹត្តខុស ចាកធម្មា
លុះពេលក្រោយ មានស្មារតី ដឹងអាត្មា
មានប្រាជ្ញា សារត្រឡប់ ប្រព្រឹត្តល្អ ។
បុគ្គលនោះ ពិតល្បីឈ្មោះ ពីរោះថា
ញុំាងលោកា ឱ្យភ្លឺថ្លា ថ្លៃបវរ
ដូចព្រះចន្ទ្រ ពេលរាត្រី រះចេញចរ
ពន្លឺល្អ ផុតស្រឡះ ចាកពពក ។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ឌ.***

## គាថាទី ១៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះអង្គុលិមាលត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**យស្ស បាបំ កតំ កម្មំ**
**កុសលេន បិធីយតិ**
**សោមំ លោកំ បភាសេតិ**
**អព្ភា មុត្តោវ ចន្ទិមា ។**

បុគ្គលណាធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះ ដោយកុសលគឺអរហត្តមគ្គបាន បុគ្គលនោះឈ្មោះថា ញុំាងខន្ធាទិលោកនេះឱ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រផុតចាកពពក ។



# EVIL CAN BE ERASED BY GOOD

Whosoever, by a good[1] deed, covers the evil[2] done, such a one illumines this world like the moon freed from clouds.

---

1. By the Path of Arahanthood.

2. One has to reap the effects of one's Kamma. But one is not bound to reap the effects of all actions one has done in the course of Saṁsāra If one were, an escape from birth and death would be impossible. At times it is possible to obliterate one's evil kamma by performing powerful good kamma.

វិបុគ្គលណា ធ្លាប់ភ្លេចអាត្មា បានធ្វើបាបហើយ
លុះដឹងស្មារតី មិននៅកន្តើយ ស្រវារកត្រើយ
សាងអរិយមគ្គ ។

គួបផ្សំនឹងបុណ្យ ដែលជាដើមទុន ដ៏ច្រើនអន័ត្ឃ
ដែលខ្លួនសន្សំ ក្នុងសង្សារចក្រ ញ៉ាំងអរហត្តមគ្គ
ឱ្យកើតឡើងបាន ។

វិបុគ្គលនោះ មានឈ្មោះពីរោះ ទៅគ្រប់ទីឋាន
គឺអាចញ៉ាំងលោក ឱ្យភ្លឺច្បាស់បាន ដូចជាព្រះចន្ទ
រួចចាកពពក ។

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***



## គាថាទី ១៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង ចេតិយ ឈ្មោះអគ្គាឡវៈ ទ្រង់ប្រារព្ធនូវធីតានៃជាង តម្បាញម្នាក់ ទើបត្រាស់នូវព្រះគាថានេះថា

**អន្ធភូតោ អយំ លោកោ**

**តនុកេត្ថ វិបស្សតិ**

**សកុណោ ជាលមុត្តោវ**

**អប្បោ សគ្គាយ គច្ឆតិ ៕**

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្ដាជនទាំងនេះ ជនតិចគ្នាដែលឃើញច្បាស់ (នូវខន្ធាទិលោកនេះ ដោយអំណាចអនិច្ចលក្ខណៈជាដើម) ជនតិចគ្នា ដែលទៅកាន់ស្ថានសួគ៌ ដូចសត្វស្លាប (ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ ។



# FEW ARE THE CLEAR-SIGHTED

Blind is this world. Few are those who clearly see. As few birds escape from a net, few go to a blissful state.[1]

1. Sagga — blissful states, not eternal heavens.

ពួកជនច្រើនពេកពិត   សុទ្ធងងឹតអន្ធការ
មានសត្វលោកតិចគ្នា   បានដឹងច្បាស់ក្នុងកងធម៌ ។
សូម្បីក្រោយពេលស្លាប់   ចាប់កំណើតក្នុងភពល្អ
ឋានសួគ៌គួរត្រេកអរ   ក៏សត្វលោកបានតិចគ្នា ។
ប្រៀបដូចបក្សីសត្វ   ដែលភ្លាំងភ្លាត់ភ្លេចអាត្មា
ជាប់លប់ព្រានកាលណា   មានតិចគ្នាដែលរួចបាន ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***



## គាថាទី ១៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយ ប្រមាណ ៣០ រូប ទើបត្រាស់នូវព្រះគាថានេះថា

**ហំសាទិច្ចបថេ យន្តិ**
**អាកាសេ យន្តិ ឥទ្ធិយា**
**នីយន្តិ ធីរា លោកម្ហា**
**ជេត្វា មារំ សវាហនំ ។**

ពួកហង្សតែងហើរទៅក្នុងគន្លងផ្លូវព្រះអាទិត្យ អ្នកមានឫទ្ធិ តែងហោះទៅក្នុងអាកាស ដោយឫទ្ធិ អ្នកប្រាជ្ញ ផ្ចាញ់កិលេសមារព្រមទាំងវាហនៈ គឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញចាកលោកបាន ។

# THE WISE SEEK AN ESCAPE FROM THIS WORLD

Swans wing along on the path of the sun. (Men) go through air by psychic powers.[1] The wise are led away from the world,[2] having conquered Māra and his host.[3]

---

1. Iddhi. By mental development it is possible to fly through the air, walk on water, dive into the earth, etc. Such kinds of powers are psychic and supernormal, but not miraculous.

2. That is, the Arahants attain Parinibbāna without coming into birth again.

3. The host of Māra, the Evil One, is described as comprising ten kinds of passions (kilesa). They are: 1. material pleasures (kāma). 2. aversion for the Holy Life (arati), 3. hunger and thirst (khuppipāsā), 4. craving (taṇhā), 5. sloth and torpor (thinamiddha), 6. fear (bhaya), 7. doubt (vicikicchā), 8. detraction and obstinacy (makkha-thambha), 9. gain (lābha), praise (siloka) honour (sakkāra) and ill gotten fame (yasa),
10. Extolling of oneself and contempt for others (attukkaṁsana-para-vambhana).



ពួកសត្វហង្ស តែងហោះហើរ តាមគន្លង
មិនឱ្យឆ្គង គឺគន្លង ព្រះអាទិត្យ
រីចំណែក ផ្នែកខាងអ្នក ដែលមានឫទ្ធិ
ពូកែពិត តែងហោះទៅ ក្នុងអាកាស ។
ឯអ្នកប្រាជ្ញ តែងតែផ្ចាញ់ កិលេសមារ
និងតណ្ហា មូលវដ្តៈ ដ៏ក្រៃក្រាស់
ប្រៀបដូចជា វាហនៈ ពុកកញ្ជាស់
ហើយរលាស់ ដោះខ្លួនចេញ ចាកលោកបាន។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវនាងបរិព្វាជិកា ឈ្មោះចិញ្ចាមាណវិកា ទើបត្រាស់នូវព្រះគាថានេះថា

**ឯកំ ធម្មំ អតីតស្ស**
**មុសាវាទិស្ស ជន្តុនោ**
**វិតិណ្ណបរលោកស្ស**
**នត្ថិ បាបំ អការិយំ ។**

បុគ្គលប្រព្រឹត្តកន្លង (ពាក្យសច្ចៈ) ដែលជាធមិឯក និយាយតែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថា មិនធ្វើអំពើបាបមិនមែនឡើយ ។



# THERE IS NO EVIL THAT A LIAR CANNOT COMMIT

There is no evil that cannot be done by the liar,[1] who has transgressed the one law (of truthfulness) and who is indifferent to a world beyond.

---

1. An untruthful person, devoid of self-respect, who has no belief in an after life and who has no fear for the attendant consequences of evil, is liable to commit any evil. Such a person does not see earthly bliss or heavenly bliss or Nibbānic bliss (Commentary).

បើត្រឹមតែពោលពាក្យសច្ចៈ

តួញថាលំបាកធ្វើទៅហើយ

ចុះបាបដទៃធ្វើម្ដេចឡើយ

ព្រងើយមិនធ្វើម្ដេចនឹងបាន ។

មនុស្សគេតែងយកសម្ដី

ដីរយកភ្លុកជាប្រមាណ

នេះជាទំនុកចាស់បុរាណ

សន្ដានចូរចាំកុំបំភ្លេច ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**



## គាថាទី ១៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវអសទិសទាន ទើបត្រាស់នូវព្រះគាថានេះថា

**ន វេ កទរិយា ទេវលោកំ វជន្តិ**

**ពាលា ហវេ នប្បសំសន្តិ ទានំ**

**ធីរោ ច ទានំ អនុមោទមានោ**

**តេនេវ សោ ហោតិ សុខី បរត្ថ ៕**

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះលោកតែងបានសេចក្ដីសុខ ក្នុងលោកខាងមុខ ។

# THE STINGY ARE NOT HAPPY

Verily, misers go not to the celestial realms. Fools do not indeed praise liberality. The wise man rejoices in giving and thereby becomes happy thereafter.



អ្នកកំណាញ់ កំណាញ់ពិត ឥតចាគា
លុះដល់គ្រា លាចាកឋាន តែងសោយសោក
ព្រោះមិនបាន ទៅកាន់ឋាន ទេវលោក
ធ្លាក់ទៅរក ទទួលទុក្ខ ក្នុងអបាយ ។
ពួកជនពាល មិនសរសើរ នូវទានឡើយ
ធ្វើព្រងើយ ហើយបង្អាប់ ទានទាំងឡាយ
ឯអ្នកប្រាជ្ញ តែងសាទរ អរសប្បាយ
សុខចិត្តកាយ ទាំងលោកនេះ និងលោកនាយ ។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវមាណពជាបុត្រនៃអនាថ-បិណ្ឌិកសេដ្ឋីឈ្មោះកាលៈ ទើបត្រាស់នូវព្រះគាថានេះថា

**បឋព្យា ឯករជ្ជេន**

**សគ្គស្ស គមនេន វា**

**សព្វលោកាធិបច្ចេន**

**សោតាបត្តិផលំ វរំ ។**

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ស្ថានសួគ៌ផង ជាងភាពជាធំ ក្នុងលោកទាំងមូលផង ។



## SPIRITUAL ADVANCEMENT IS BETTER THAN WORLDLY SOVEREIGNTY

Better than absolute sovereignty[1] over the earth, better than going to heaven, better than even lordship over all the worlds is the Fruit of a Stream-Winner.[2]

---

1. Internal purification is far superior to fleeting worldly possessions or transitory heavenly bliss.

2. Sotāpatti. Here Sota means the stream that leads to Nibbāna. It is the noble Eightfold Path. 'Ā'means for the first time. 'Patti' means attainment, Sotāpatti means the attainment of the stream for the first time. It is the realization of Nibbāna for the first time. This is the first stage of Sainhood. The Stream-Winners are not born in woeful states.

ភាពឯករាជ្យនៅលើផែនដី

មានជនប្រុសស្រីអបអរសាទរ

ឬមួយការបាននូវគតិល្អ

កើតឋានបវរគឺសួគ៌ាល័យ ។

ឬភាពជាធំលើលោកទាំងអស់

តែទាស់ចុងក្រោយជីវិតត្រូវក្ស័យ

សោតាបត្តិផលទើបប្រសើរក្រៃ

ជាងសម្បត្តិបីខាងលើនុ៎ះឯង ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***



## គាថាទី ២១[១]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងប្រទេសជាទីផ្លូវផង់នៃពោធិញ្ញាណ ទ្រង់ប្រារព្ធនូវធីតារបស់មារទាំងឡាយ ទើបត្រាស់នូវព្រះគាថានេះថា

**យស្ស ជិតំ នាវជីយតិ**

**ជិតមស្ស នោយាតិ កោចិ លោកេ**

**តំ ពុទ្ធំ អនន្តគោចរំ**

**អបទំ កេន បទេន នេស្សថ ។**

**យស្ស ជាលិនី វិសត្តិកា**

**តណ្ហា នត្ថិ កុហិញ្ចិ នេតវេ**

**តំ ពុទ្ធំ អនន្តគោចរំ**

**អបទំ កេន បទេន នេស្សថ ។**

---

១-បើរាប់តាមលំដាប់ក្នុងពុទ្ធវគ្គ ត្រូវជាគាថា ទី ១

ជ័យជម្នះ របស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយក្នុងលោករមែងមិនជាប់តាមជ័យជម្នះ របស់ព្រះពុទ្ធអង្គនោះ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចររកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្ដេចកើត ។

តណ្ហា ដែលមានបណ្ដាញ ផ្សាយទៅក្នុងអារម្មណ៍ផ្សេង ៗ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅក្នុងភពណាមួយ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្ដេចកើត ។



# THE BUDDHA CANNOT BE FATHOMED

Whose conquest (of passion) is not turned into defeat,[1] not conquered (passion) of his in this world follows him[2] – that trackless[3] Buddha of infinite range,[4] by which way will you trace him?

---

1. As the Buddha had eradicated all passions of lust, hatred, and delusion they could not arise in him any more. His spiritual victory was unconquerable.
2. Because the eradicated passions do not arise again.
3. Since the Buddha is devoid of the tracks (pada) of lust, hatred, and delusion.
4. Being omniscient.

# THE BUDDHA IS PASSIONLESS

Him in whom there is not that entangling,[5] embroiling craving to lead (to any life), him the trackless Buddha of infinite range,- by which way will you trace him ?[6]

5. Of lust, hatred, and delusion.
6. Nessatha = will lead to temptation by bringing under the sway of the tempters.



ព្រះមុនិន្ទលោកាចារ្យ    មានបញ្ញារុងរឿងថ្កាន

កិលេសធមិសាមាន្យ    ព្រះអង្គឈ្នះគ្រប់ប្រការ ។

តណ្ហាដែលផ្សាយទៅ    ជាប់នៅក្នុងអារម្មណ៍ណា

មិនមានក្នុងចិន្តា    ព្រះឈ្នះមារអង្គនោះឡើយ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ខ.**

## គាថាទី ២២

សម័យមួយ ព្រះមានព្រះភាគទ្រង់ប្រារព្ធនូវទេវតានិងមនុស្សទាំងឡាយច្រើន ទៀបទ្វារនៃនគរឈ្មោះសង្កស្ស: ទើបត្រាស់ នូវព្រះគាថានេះថា

**យេ ឈានប្បសុតា ធីរា**

**នេក្ខម្មូបសមេ រតា**

**ទេវាបិ តេសំ បិហយន្តិ**

**សម្ពុទ្ធានំ សតីមតំ ។**

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយ ក្នុងឈាន ត្រេកអរក្នុងនេក្ខម្ម:ជាឋានស្ងប់រម្ងាប់កិលេស សូម្បី ទេវតានិងមនុស្សទាំងឡាយតែងរាប់រក ចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯង ទាំងមានស្មារតី ។



## BUDDHAS ARE DEAR TO ALL

The wise ones who are intent on meditation,[1] who delight in the peace of renunciation[2] (i.e. Nibbāna), such mindful perfect Buddhas even the gods hold (most) dear.

---

1. Here Jhāna means both concentration (samatha) and insight (Vipassanā).
2. Nekkhamma implies Nibbāna, which is gained by the subjugation of passions.

ពួកអ្នកប្រាជ្ញ រុងរឿងស្វាច ដោយបញ្ញា
មានចិន្តា ស្ងប់រម្ងាប់ នៅក្នុងឈាន
ត្រេកអរក្នុង នេក្ខម្មៈ ដែលជាឋាន
សុខក្សេមក្សាន្ត ឋានមិនមាន កិលេសក្បែរ ។
សូម្បីតែ ទេវតា និងមនុស្ស
មិនប្រទូស្ត តែងរាប់អាន ជាហូរហែ
ដោយលោកបាន ត្រាស់ដឹងធម៌ ឥតប្រួលប្រែ
រាល់ថ្ងៃខែ មានស្មារតី ជាប់ជានិច្ច ។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***



## គាថាទី ២៣

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ទៀបគល់នៃដើមច្រេស ៧ ជាយក្រុងពារាណសី ទ្រង់ប្រារព្ធនូវស្តេចនាគ ឈ្មោះឯរកបត្ត ទើបត្រាស់នូវព្រះគាថានេះថា

**កិច្ឆោ មនុស្សបដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។**

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ ។

# THE GOOD ARE RARE

Rare is birth as a human being. Hard is the life of mortals. Hard is the hearing of the Sublime Truth. Rare is the appearance of the Buddhas.



ការមានភ័ព្វ ត្រឡប់កើត បានចំពោះ
ជាមនុស្ស សត្វតែងបាន ដោយកម្រ
ការរស់នៅ សុខក្សេមក្សាន្ត សត្វលោកក៏
បានដោយក្រ កម្របាន តាមប្រាថ្នា ។
ការត្រងត្រាប់ ស្តាប់ព្រះធម៌ សប្បុរស
ដ៏ពីរោះ ពិតជាក្រ ក្នុងលោកា
ការកើតឡើង នៃព្រះពុទ្ធ ជាសាស្ដា
ទ្រង់ត្រាស់ថា ពិតជាក្រ មានក្នុងលោក ។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២៤

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវបញ្ហារបស់ព្រះអានន្ទ ទើបត្រាស់នូវព្រះគាថានេះថា

**សព្វបាបស្ស អករណំ**
**កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ**
**ឯតំ ពុទ្ធាន សាសនំ ៗ**
**ខន្តី បរមំ តបោ តីតិក្ខា**
**និព្វានំ បរមំ វទន្តិ ពុទ្ធា**
**ន ហិ បព្វជិតោ បរូបឃាតី**
**សមណោ ហោតិ បរំ វិហេឋយន្តោ ៗ**



**អនូបវាទោ អនូបឃាតោ**
**បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ**
**បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ**
**ឯតំ ពុទ្ធាន សាសនំ ៗ**

ការមិនធ្វើបាបទាំងពួង ការញ៉ាំងកុសលឱ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

ខន្តិ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយ តែងពោលថា ព្រះនិព្វាន ជាធម្មជាតដ៏ឧត្តម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះ

ថា បព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថា សមណៈឡើយ ។

ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួមក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត ១ ការដេកនិងអង្គុយក្នុងទីស្ងាត់ ១ ការព្យាយាមក្នុងអធិចិត្ត ១ នុ៎ះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។



# DO GOOD AND BE GOOD

Not to do any evil,[1] to cultivate good, to purify one's mind,—this is the Teaching of the Buddhas.[2]

---

1. What is associated with the three immoral roots of attachment (lobha), illwill (dosa), and delusion (moha) is evil. What is associated with the three moral roots of generosity (alobha), goodwill or loving –kindness (adosa), and wisdom (amoha) is good.

2. The religion of the Buddha is summariesd in this verse.

~ ៧៨ ~

## NON-VIOLENCE IS THE CHARACTERISTIC OF AN ASCETIC

Forbearing patience is the highest austerity. Nibbāna is supreme, say the Buddhas. He, verily, is not a recluse[3] who harms another. Nor is he an ascetic[4] who oppresses others.

3. Pabbajito, one who casts aside his impurities, and has left the world.

4. Samaṇo, one who has subdued his passions, an ascetic.

~ ៧៩ ~

## LEAD A PURE AND NOBLE LIFE

Not insulting, not harming, restraint according to the Fundamental Moral Code,[5] moderation in food, secluded abode, intent on higher thoughts,[6] – this is the Teaching of the Buddhas.

5.Pātimokkha, these are the 220 chief rules (excluding the seven ways of settling disputes) which every bhikkhu is expected to observe.

6.Adhicitta, – namely, the eight attainments (aṭṭhasamāpatti), the four rūpa jhānas and the four arupa jhānas. They are higher stages of mental concentration which enable one to gain supernormal powers.

ការដែលមិនធ្វើបាប ឬកសុភាពសាងកុសល
ចុងក្រោយខំតម្កល់ អប់រំចិត្តឱ្យបានស្អាត ។
ទាំងនេះជាសំណៅ ពាក្យប្រដៅព្រះលោកនាថ
មិនគប្បីប្រមាទ ត្រូវសង្វាតគ្រប់អាត្មា ។
ខន្តីក្តីអត់ធន់ គឺជាទុននៃកុសលា
និព្វានទ្រង់ត្រាស់ថា ជាគុណជាតដ៏ឧត្តម ។
អ្នកបៀតបៀនប្រហារ សត្វផងគ្នាឱ្យទួញយំ
អ្នកនោះមិនសក្តិសម នឹងនាមថាសមណៈឡើយ ។
ទាំងនេះជាសំណៅ ពាក្យប្រដៅ ........... ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ខ.***



## គាថាទី ២៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុអ្នកមិនត្រេកអរចំពោះ (ព្រហ្មចរិយៈ) មួយរូប ទើបត្រាស់នូវព្រះគាថានេះថា

**ន កហាបណវស្សេន**
**តិត្តិ កាមេសុ វិជ្ជតិ**
**អប្បស្សាទា ទុក្ខា កាមា**
**ឥតិ វិញ្ញាយ បណ្ឌិតោ**
**អបិ ទិព្វេសុ កាមេសុ**
**រតឹ សោ នាធិគច្ឆតិ**
**តណ្ហក្ខយរតោ ហោតិ**
**សម្មាសម្ពុទ្ធសាវកោ ៕**

ការស្កប់ស្កល់ក្នុងកាមទាំងឡាយរមែងមិនមាន ព្រោះកហាបណៈ (ដែលធ្លាក់ចុះ) ដូចទឹកភ្លៀងទេ កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញ ដឹងច្បាស់យ៉ាងនេះហើយ លោកមិនបានត្រេកអរក្នុង កាមទាំងឡាយ សូម្បីជាទិព្វឡើយ សាវ័ករបស់ ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរក្នុងធមិជាគ្រឿង អស់តណ្ហា ។



# INSATIABLE ARE SENSUAL PLEASURES

Not by a shower of gold coins does contentment arise in sensual pleasures. Of little sweetness, and painful, are sensual pleasures. Knowing thus, the wise man finds no delight even in heavenly pleasures. The disciple of the Fully Enlightened One delights in the destruction of craving.

ការស្តាប់ស្គាល់ យល់ថាគ្រប់ ដោយកាមា
ទ្រង់ត្រាស់ថា មិនដែលមាន ក្នុងលោកីយ៍
ទោះជាទ្រព្យ ធ្លាក់ដូចភ្លៀង ពេញផែនដី
ក៏គ្មានអ្វី អាចបំពេញ តណ្ហាបាន ។
តែអ្នកប្រាជ្ញ លោកអ្នកមាន បញ្ញាក្រាស់
បានដឹងច្បាស់ នូវធម្មា ទៅដោយញាណ
ឃើញលោកនេះ មិនឋិតនៅ យូរប៉ុន្មាន
លោកមិនបាន ឈ្លក់វង្វេង ត្រេកអរឡើយ ។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***



# គាថាទី ២៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅលើគំនរនៃដីខ្សាច់ ទ្រង់ប្រារព្ធនូវបុរោហិតនៃព្រះរាជាដែនកោសល ឈ្មោះអគ្គិទត្តៈ ទើបត្រាស់នូវព្រះគាថានេះថា

**ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច**
**អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា**
**នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ**
**នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។**
**យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ**
**ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ**

ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ

អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ

ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ

ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

មនុស្សទាំងឡាយច្រើននាក់ ត្រូវភ័យគម្រាម ហើយ តែងយកភ្នំ អារាមនិងរុក្ខចេតិយ ជាទីពឹង ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែប នេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យ នូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួង ឡើយ ។



លុះតែបុគ្គលណាយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺ ទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ច កន្លងទុក្ខ ១ អរិយមគ្គ ប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ ព្រះនិព្វាន ដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯង ជាទីពឹងដ៏ក្សេម នេះឯងជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យ ទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

# DON'T SEEK REFUGE ELSEWHERE

When threatened with danger, men go to many a refuge,—to hills, woods, groves, trees and shrines.

But such a refuge is not a safe refuge, not the best refuge. One is not liberated from all evil consequences of existence (dukkha) for having come to such a refuge.



# SEEK REFUGE IN THE BUDDHA, DHAMMA AND SANGHA

He who has gone for refuge to the Buddha, the Dhamma, and the Sangha,[1] sees with right knowledge the four Noble Truths: Sorrow, the Cause of Sorrow, the Transcending of Sorrow and the Noble Eightfold Path which leads to the Cessation of Sorrow.

---

1. One's best refuge is oneself. A Buddhist seeks refuge in the Buddha, the Dhamma and the Sangha as the Teacher, the Teaching and the Taught in order to gain his deliverance from the ills of life. The Buddha is the supreme teacher who shows the way to deliverance. The Dhamma is the unique way.

This, indeed, is refuge, secure. This, indeed, is refuge supreme. By seeking such refuge one is released from all sorrow.

---

The Sangha represents the Taught who have followed the way and have become living examples. One formally becomes a Buddhist by intelligently seeking refuge in this Triple Gem (Tisaraāa). A Buddhist does not seek refuge in the Buddha with the hope that he will be saved by a personal act of deliverance. The confidence of a Buddhist in the Buddha is like that of a sick person in a noted physician, or if a student in his teacher.



មានភ័យគ្របសង្កត់ សត្វតែងរត់រកទីពឹង<br>
តែសត្វលោកមិនដឹង នូវទីពឹងអ្វីត្រូវពិត ។<br>
ខ្លះទៅពឹងបព្វតា ឬរុក្ខាព្រោះភ័យភិត<br>
ខ្លះទៀតមិនបានគិត ពឹងអារាមនិងចេតិយ ។<br>
ទីពឹងទាំងអស់ហ្នឹង មិនអាចពឹងបានពិតអី<br>
ព្រោះលើភពផែនដី តែងប្រែប្រួលគ្មានលំនឹង ។<br>
លុះតែយកត្រៃរតន៍ ប្រសើរផុតជាទីពឹង<br>
ទើបផុតភ័យទាំងហ្នឹង ព្រោះដឹងផ្លូវទៅនិព្វាន ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវបញ្ហារបស់ព្រះអានន្ទ ទើបត្រាស់នូវព្រះគាថានេះថា

**ទុល្លភោ បុរិសាជញ្ញោ**
**ន សោ សព្វត្ថ ជាយតិ**
**យត្ថ សោ ជាយតី ធីរោ**
**តំ កុលំ សុខមេធតិ ។**

បុរសអាជានេយ្យ រកបានដោយកម្រ លោកមិនកើតក្នុងសព្វឋានឡើយ លោកជាអ្នកមានប្រាជ្ញាកើតក្នុងត្រកូលណា ត្រកូលនោះ តែងដល់នូវសេចក្ដីសុខ ។



## THE NOBLE ARE RARE

Hard to find is a man of great wisdom: such a man is not born everywhere. Where such a wise man is born, that family thrives happily.

បុរសមានឈ្មោះអាជានេយ្យ
ក្នុងភពផែនដីពិតជាក្រ
លោកបានឃើញផ្លូវត្រឹមត្រូវល្អ
ឈប់មានកំណកំណើតថ្មី ។
លោកគឺជាអ្នកមានប្រាជ្ញា
តែងតែភ្លឺថ្លាដោយស្មារតី
តែងនាំមកនូវសុខសួស្តី
ដល់ជនប្រុសស្រីក្នុងត្រកូល ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***



## គាថាទី ២៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវសំដីរបស់ភិក្ខុទាំងឡាយច្រើនរូប ទើបត្រាស់នូវព្រះគាថានេះថា

**សុខោ ពុទ្ធានមុប្បាទោ**
**សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី**
**សមគ្គានំ តបោ សុខោ ។**

ការកើតឡើងនៃព្រះពុទ្ធជាសុខ ការសំដែងព្រះសទ្ធម្មជាសុខ សេចក្តីព្រមព្រៀងគ្នានៃពួកជាសុខ តបធម៌ របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយជាសុខ ។

# THE MOST HAPPY OCCURANCES

Happy is the birth of Buddhas. Happy is the teaching of the sublime Dhamma. Happy is the unity of the Sangha.[1] Happy is the discipline of the united ones.

---

1. Sangha is the oldest, democratically constituted, historic celibate Order, founded by the Buddha. Strictly speaking, the Sangha denotes those noble disciples who have realized the four Paths and four Fruits. The ordinary bhikkhus of the present day are merely their representatives.



ការកើតនៃព្រះពុទ្ធ　　ជាចមម្កុដត្រៃលោកា
តែងនាំក្ដីសុខា　　ដល់ទ្វីបលោកទាំងយប់ថ្ងៃ ។
ការដែលសម្ដែងធម៌　　បរិសុទ្ធល្អដោយប្រពៃ
នៃសប្បុរសថ្លាថ្លៃ　　ពិតមានន័យបានសុខា ។
វីការបានព្រមព្រៀង　　ឥតមានល្អៀងក្នុងក្រុមណា
ក្រុមនោះបានសុខា　　ការទាស់គ្នាឥតមានសោះ ។
ចំណែកតបធម៌　　ចម្រើនល្អមិនមានមោះ
ការនេះបានពីព្រោះ　　គ្មានជម្លោះក្នុងពួកក្រុម ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២៩

សម័យមួយ ព្រះមានព្រះភាគទ្រង់ស្ដេចចារិក ទៅ ទ្រង់ប្រារព្ធនូវព្រះចេតិយមាស របស់ព្រះកស្សប-ទសពល ទើបត្រាស់នូវព្រះគាថានេះថា

បូជារហេ បូជយតោ
ពុទ្ធេ យទិ ច សាវកេ
បបញ្ចសមតិក្កន្តេ
តិណ្ណសោកបរិទ្ទវេ
តេ តាទិសេ បូជយតោ
និព្វុតេ អកុតោភយេ
ន សក្កា បុញ្ញំ សង្ខាតុំ
ឥមេត្តមបិ កេនចិ ។



កាលបុគ្គលបូជា ដល់បូជារហបុគ្គលគឺព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្ដីសោកនិងខ្សឹកខ្សួល ឬកាលបូជាដល់បូជារហបុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណា ស្ងប់រម្ងាប់និព្វានទៅហើយ បុគ្គលណាមួយ មិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណោះបានឡើយ ។

# HONOUR TO WHOM HONOUR IS DUE

He who reverences those worthy of reverence, whether Buddhas or their disciples; those who have overcome the impediments[1] and have got rid of grief and lamentation,—the merit of him who reverences such peaceful[2] and fearless ones[3] cannot be measured by anyone. as such and such .

---

1. Papañca = impediments or obstacles such as attachment, false views and pride.
2. Those who have extinguished the fire of lust.
3. The passionless are fearless.



បូជាដល់បុគ្គល អ្នកបានដល់ព្រះនិព្វាន
បូជាព្រះទ្រង់ញាណ ឬសាវ័កព្រះសាស្តា ។
ជាអ្នកបានឆ្លងផុត នូវវាលវដ្តសង្សារ
មិនមាននូវតណ្ហា ដែលជាបបញ្ចធម៌ ។
មិនមានការខ្សឹកខ្សួល រំជួលយំឬត្រេកអរ
គង់ក្នុងវិហារធម៌ ស្ងប់រម្ងាប់ឥតមានភ័យ ។
វិផលការបូជា ចេញផ្លែផ្កាច្រើនពេកក្រៃ
ក្នុងក្បួនគណនេយ្យ លៃរៀបរាប់ពុំបានឡើយ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

## គាថាទី ៣០[១]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងដែនសក្កៈ ទ្រង់ប្រារព្ធនូវព្រះញាតិទាំងឡាយ ដើម្បីរម្ងាប់នូវជម្លោះ ទើបត្រាស់នូវព្រះគាថានេះថា

**សុសុខំ វត ជីវាម វេរិនេសុ អវេរិនោ**
**វេរិនេសុ មនុស្សេសុ វិហរាម អវេរិនោ ។**
**សុសុខំ វត ជីវាម អាតុរេសុ អនាតុរា**
**អាតុរេសុ មនុស្សេសុ វិហរាម អនាតុរា ។**
**សុសុខំ វត ជីវាម ឧស្សុកេសុ អនុស្សុកា**
**ឧស្សុកេសុ មនុស្សេសុ វិហរាម អនុស្សុកា ។**

---

-បើរាប់តាមលំដាប់ក្នុងសុខវគ្គ ត្រូវជាគាថា ទី ១



យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្សមានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ ។

យើង ជាអ្នកមិនមានសេចក្តីក្តៅក្រហាយ (ដោយកិលេស) រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីក្តៅក្រហាយ កាលពួកមនុស្សមានសេចក្តីក្តៅក្រហាយ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ។

យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ក្នុងការស្វែងរក រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ កាលពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ។

# AMONGST THE HATEFUL BE WITHOUT HATE

Ah, happily do we live without hate amongst the hateful; amidst hateful men we dwell unhating.

# AMONGST THE SICK BE IN GOOD HEALTH

Ah, happily do we live in good health[1] amongst the ailing; amidst ailing men we dwell in good health.

---

1. Free from the disease of passions.



# AMONGST THE PASSIONATE BE WITHOUT PASSION

Ah, happily do we live without yearning (for sensual pleasures) amongst those who yearn (for them); amidst those who yearn (for them) we dwell without yearning.

មនុស្សទាំងឡាយកំពុងមានពៀរ

យើងអស់វេរារស់នៅសុខពិត

មនុស្សកំពុងក្តៅក្រហាយចិត្ត

តថាគតពិតបានក្តីសុខា ។

ពួកមនុស្សខ្វល់ខ្វាយក្នុងការស្វែងរក

យើងព្រះមានជោគតែងស្ងប់ចិន្តា

ព្រោះយើងផ្តាច់ផ្តិលឫសគល់តណ្ហា

ទុក្ខសោកខ្លោចផ្សាមិនមានទៀតឡើយ ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ **ស.ស.ជ.***



## គាថាទី ៣១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងស្រុកនៃព្រាហ្មណ៏ឈ្មោះបញ្ចសាលា ទ្រង់ប្រារព្ធនូវមារទើបត្រាស់នូវព្រះគាថានេះថា

**សុសុខំ វត ជីវាម**

**យេសន្នោ នត្ថិ កិញ្ចនំ**

**បីតិភក្ខា ភវិស្សាម**

**ទេវា អាភស្សរា យថា**

យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត (ព្រោះ) យើងមានបីតិជាអាហារ ដូចពួកទេវតាជាន់អាភស្សរៈ ។

# BE WITHOUT IMPEDIMENTS

Indeed we live very happily, without any impediments.[1] Like the Ābhassara Brahmās we shall live on delightful satisfaction (pīti) as our food.

---

1. Kiñcana, such as lust, hatred, and delusion which are hindrances to spiritual progress.



នៅក្នុងជីវិត តថាគតពិត ឥតមានកង្វល់
អស់នូវកិលេស ជាគ្រឿងអម្ពល់ ក្នុងចិត្តយើងសល់
តែក្តីសុខា ។

យើងរស់ជាសុខ ឥតមានក្តីទុក្ខ ចាក់រុកចិន្តា
យើងមានបីតិ គឺជាអាហារ ដូចពួកព្រហ្មា
ជាន់អាភស្សរះ ។

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៣២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវការបរាជ័យរបស់ព្រះរាជាដែនកោសល ទើបត្រាស់នូវព្រះគាថានេះថា

**ជយំ វេរំ បសវតិ**
**ទុក្ខំ សេតិ បរាជិតោ**
**ឧបសន្តោ សុខំ សេតិ**
**ហិត្វា ជយបរាជយំ ៕**

បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលអ្នកចាញ់ តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះ និងការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។



## VICTORY BREEDS HATRED

Victory breeds hatred. The defeated live in pain. Happily the peaceful live, giving up victory and defeat.

បុគ្គលអ្នកឈ្នះតែងមានពៀរ

អ្នកចាញ់គ្រាំគ្រាដេកជាទុក្ខ

លះការឈ្នះចាញ់ទើបបានសុខ

ជាតិនេះជាតិមុខអស់វេរា ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**



## គាថាទី ៣៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវនាងកុមារិកាមួយរូប ទើបត្រាស់នូវព្រះគាថានេះថា

**នត្ថិ រាគសមោ អគ្គិ**

**នត្ថិ ទោសសមោ កលិ**

**នត្ថិ ខន្ធសមា ទុក្ខា**

**នត្ថិ សន្តិ បរំ សុខំ ។**

ភ្លើងស្មើដោយរាគៈ មិនមាន ទោសកំហុសស្មើដោយទោសៈ មិនមាន ទុក្ខទាំងឡាយស្មើដោយខន្ធ មិនមាន សុខក្រៅពីសេចក្ដីស្ងប់ មិនមាន ។

# LUST IS A FIRE

There is no fire like lust, no crime like hate. There is no ill like the body,[1] no bliss higher than Peace (Nibbāna).

1. Pacakkhandha the five Aggregates.



ភ្លើងក្តៅស្មើរាគៈ ក្នុងលោកជាក់រកមិនបាន
រាគៈឆេះសព្វឋាន ដល់និព្វានទើបសុខា ។
ទោសឬកំហុសអ្វី ដែលអប្រិយគួរអារ
ស្មើទោសៈហឹនា ក្នុងលោកាពិតមិនមាន ។
ទុក្ខសោកផងទាំងឡាយ បៀតបៀនកាយចិត្តសន្តាន
ស្មើខន្ធប្រាំសាមាន្យ ពិតមិនមានក្នុងលោកា ។
រីឯសេចក្តីសុខ ដែលអស់ទុក្ខគ្រប់ប្រការ
ក្រៅពីស្ងប់សង្ខារ ទ្រង់ត្រាស់ថាមិនដែលមាន ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

# អ្នកជួយពិនិត្យខ្លឹមសារនិងអក្ខរាវិរុទ្ធ

ឧទ្ទេសាចារ្យ សុវណ្ណត្ថេរោ វង្ស ធំព័រ

ភិក្ខុ កោសលប្បញ្ញោ ទួច ពិសិដ្ឋ

ឧទ្ទេសាចារ្យ សីលសំវរោ ស៊ូ សាមុត

សាមណេរ ខន្តិធរោ ជឹម បូរិន

សាមណេរ ប្រាជ្ញ ស៊ីណា

សាមណេរ ប៊ិច វណ្ណនុច



# សៀវភៅធម៌ដែលបានរៀបរៀង

## ដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា

| | |
|---|---|
| ១.ព្រះធម្មបទ ៣៣ គាថា | ព.ស. ២៥៥២ |
| ២.សិង្គាលកសូត្រ | ព.ស. ២៥៥២ |
| ៣.ព្រះធម្មបទ ៣២ គាថា | ព.ស. ២៥៥១ |
| ៤.ដំណើរជីវិត | ព.ស. ២៥៥១ |
| ៥.ព្រះធម្មបទ ៣១ គាថា | ព.ស. ២៥៥០ |
| ៦.អក្ខរវិធីនិងធម៌នមស្ការ | ព.ស. ២៥៥០ |
| ៧.របកលោកធម៌ | ព.ស. ២៥៥០ |
| ៨.ព្រះធម្មបទ ៣០ គាថា | ព.ស. ២៥៤៩ |
| ៩.ប្រយោជន៍ ៣ ប្រការ | ព.ស. ២៥៤៩ |

# សៀវភៅធម៌ដែលបានរៀបរៀង

## ដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា

## (ត)

| | | |
|---|---|---|
| ១០.ជីវិត | (Life) | ព.ស. ២៥៤៩ |
| ១១.បងប្អូនជួបគ្នាមួយគ្រាមានន័យ | | ព.ស. ២៥៤៨ |
| ១២.អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៤ | | ព.ស. ២៥៤៨ |
| ១៣.ធម្មសង្គណី តិកមាតិកាសង្ខេប | | ព.ស. ២៥៤៨ |
| ១៤.ជីវិតពិតជាត្រូវការធម៌ | | ព.ស. ២៥៤៦ |
| ១៥.តើនរកមានដែរឬទេ ? | | ព.ស. ២៥៤៦ |

**ព្រះធម៌គឺជាប្រទីបសម្រាប់បំភ្លឺជីវិតសត្វលោក**



# កម្មវិធីផ្សព្វផ្សាយព្រះធម៌

## សម្ដែងដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា

| ខេត្ត-ក្រុង | ស្ថានីយវិទ្យុ | វេលាផ្សាយ |
|---|---|---|
| ភ្នំពេញ | FM 102.50 MHz | ៥.00 am⇨៥.៣0 am |
| សៀមរាប | FM 102.50 MHz | ៥.00 am⇨៥.៣0 am |
| កំពង់ចាម | FM 92.50 MHz | ៥.00 am⇨៥.៣0 am |
| | FM 92.50 MHz | ៧.៣0 pm⇨៨.00 pm |
| ស្ទឹងត្រែង | FM 100.50 MHz | ៥.៣0 am⇨៦.00 am |
| កំពង់ធំ | FM 98.30 MHz | ៥.៣0 am⇨៦.00 am |
| | FM 88.30 MHz | ៨.00 pm⇨៨.៣0 pm |
| កំពត | FM 99.50 MHz | ៥.៣0 am⇨៦.00 am |

# កម្មវិធីផ្សព្វផ្សាយព្រះធម៌

## សម្តែងដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា

## (ត)

| | | |
|---|---|---|
| ព្រះវិហារ | FM 99.00 MHz | ៥.៤៥ am⇨៦.១៥ am |
| ពោធិ៍សាត់ | FM 100.50 MHz | ៦.៣០ pm⇨៧.00 pm |
| | FM 98.50 MHz | ៧.00 pm (ថ្ងៃសីល) |
| តាកែវ | FM 92.50 MHz | ៦.៣០ pm⇨៧.00 pm |
| កំពង់សោម | FM 100.50 MHz | ៥.00 am⇨៦.00 am |
| | FM 92.00 MHz | ៦.៣០ pm⇨៧.00 pm |
| ស្វាយរៀង | FM 103.75 MHz | ៨.00 pm⇨៨.៣០ pm |

ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ



# អ្នកឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌

## តាមវិទ្យុក្នុងតារាងខាងលើ

១. ខេត្តស្ទឹងត្រែង FM 100.50 MHz

២. ខេត្តព្រះវិហារ FM 99.00 MHz

៣. ខេត្តស្វាយរៀង FM 103.75 MHz

ទាំង ៣ ប៉ុស្តិ៍នេះ ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយជាប្រចាំ ដោយពុទ្ធបរិស័ទ នៅទីក្រុងម៉ែលប៊ិន ប្រទេសអូស្ត្រាលី និង ពុទ្ធបរិស័ទនៅប្រទេសញូស៊ីឡែន ។

៤. ខេត្តសៀមរាប FM 102.50 MHz ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយជាប្រចាំ ដោយពុទ្ធបរិស័ទ នៅស្រុកស្ទោង ខេត្តកំពង់ធំ ។

ចំពោះការផ្សាយព្រះធម៌នៅតាមវិទ្យុ ១១ ប៉ុស្តិ៍ទៀត វិទ្យុនៅខេត្តក្រុងណា គឺពុទ្ធបរិស័ទនៅក្នុងខេត្តក្រុងនោះ ជាអ្នកឧបត្ថម្ភប្រាក់ផ្សាយជាប្រចាំ ។

# ដំណើរកសាងបទុមចេតិយ

នៅថ្ងៃព្រហស្បតិ៍ ៦ កើត ខែបុស្ស ឆ្នាំជូត សំរឹទ្ធិស័ក ព.ស.២៥៥២ ត្រូវនឹង ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៩ នេះតទៅ មណ្ឌលសិក្សាព្រះពុទ្ធសាសនា-មណីរត្ន បានចាប់ផ្ដើមកសាងព្រះចេតិយសម្រាប់តម្កល់ព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ ដែលខ្ញុំបានថ្វាយព្រះនាមថា **បទុមចេតិយ** ។

តាមពិត កាលណាបើនិយាយពីឈ្មោះចេតិយក្នុងគំនិតខ្មែរយើង ហាក់ដូចជារឿងសាមញ្ញមួយមិនមានអ្វីប្លែកទេ គឺគេសំដៅលើចេតិយសម្រាប់តម្កល់អដ្ឋិធាតុរបស់មនុស្សធម្មតាប៉ុណ្ណោះ ។ ប៉ុន្តែ **បទុមចេតិយ** នេះ មិនមែនសម្រាប់មនុស្សធម្មតាទេ



គឺសាងឡើង សម្រាប់តម្កល់តែព្រះបរមធាតុរបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ។

នេះចាត់ជាដំណឹង សម្រាប់ពុទ្ធបរិស័ទគ្រប់ទិសទី ដែលមានបំណងសាបព្រោះបន្ទុះពូជបុណ្យក្នុងព្រះពុទ្ធសាសនា ដោយកប់ទុកក្នុង **បទុមចេតិយ** ចាប់ពីពេលនេះតទៅ រហូតដល់កសាងរួច ។

នៅទំព័រខាងមុខនេះ នឹងមានរូបភាពគំនូរ **បទុមចេតិយ** ដែលនឹងត្រូវកសាង ។

**សុខោ បុញ្ញស្ស ឧច្ចយោ**

**កិរិយាសន្សំបុណ្យ**

**នាំមកនូវសេចក្ដីសុខ**




គម្រោងសាងសង់បទុមចេតិយ



## អធិប្បាយពន្យល់

(1) កន្លែងតម្កល់ព្រះសារីរិកធាតុ ។

(2) កំពូលចេតិយ មើលទៅឃើញ ៧ ជាន់ ក្នុងមួយជាន់ ៧ ស្រោបដោយត្របកផ្កាឈូក ហើយក្នុងត្របកផ្កាឈូកនីមួយ ៗ សុទ្ធតែមានតម្កល់ព្រះពុទ្ធរូបទាំងអស់ ។

(3) តួចេតិយខាងលើមានទំហំ ៨ ម៉ែត្រ ដោយគិតតាមអង្កត់ផ្ចិត ។ ជញ្ជាំងខាងជើង ឆ្លាក់រូបប្រសូតិខាងកើត ត្រាស់ដឹង ខាងត្បូង សម្តែងព្រះធម្មចក្រខាងលិច បរិនិព្វាន ។

(4) ជុំវិញចេតិយ តម្កល់ព្រះពុទ្ធរូប ២៨ អង្គ ។

(5) មាត់ផ្កាឈូកមានទំហំ ១៨ ម៉ែត្រ ដោយគិតតាមអង្កត់ផ្ចិត ។

⑥ ត្របកផ្កាឈូកមានកំពស់ ៧ ម៉ែត្រ ។

⑦ ពីបាតផ្កាឈូកដល់កំពូលចេតិយ មានកំពស់ ៤១ ម៉ែត្រ ។

សូមបញ្ជាក់ថា បទុមចេតិយ នេះ នឹងត្រូវកសាងនៅក្នុងស្រះទឹកទំហំ ៣០ម x ៤៦ម ។ ហើយសព្វថ្ងៃទើបតែចាប់ផ្តើមជីកស្រះ និងចាក់បេតុងទប់មាត់ស្រះ និងបាតស្រះ ។

ពត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈ ឧបាសិកា **ជា កែវមុនី**

ទូរស័ព្ទលេខ ០១៦ ៧២១ ០៨៨ ។

**បោះពុម្ពលើកទី ១**

**ចំនួន ១០០០០ ក្បាល**

**រោងពុម្ព អ៊ឹម សាវ័ន្ត**

